Theology on the Web.org.uk
Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

HONEYCOMB 4/1 (January): 106–116



# Portrait of a Leader

*Russell H. BOWERS, Jr.*

Pol Pot, Mother Teresa, Hun Sen, Heng Cheng, George Bush, Yassir Arafat, Gautama Buddha, Osama bin Laden. What do all these people have in common?

They are leaders. For good or for ill, with evil intent or noble, they have stood at the front and rallied compatriots to follow. The fortunes of millions have been shaped by these few.

A good leader is beyond price. Where would people be without his or her inspiration, courage, determination, and wisdom? Would not their hopes have evaporated? By contrast, an evil leader can cause unspeakable woe or embarrassment to his followers. Examples are too many and too painful to recite.

How can we find the one and avoid the other? How can we *become* the one and not the other? In Cambodia where the church is growing at warp speed, we labor to train a new generation of leaders. For what shall we aim? What qualities should we seek to find and produce?

This article cannot fully answer those questions. But let me suggest five characteristics for starters. These qualities may be useful for many kinds of leaders. But particularly in the church, a good leader is someone who:

- *follows*
- *serves*
- *builds*
- *leads*
- *passes on the baton.*

## A Good Leader Follows

It may seem an inversion to talk about a *leader* being a *follower*. Leaders, we are told, stand at the front, point the way, and issue commands. But the best leaders started out as good followers. How can a leader know how the chain of command works unless he has experience in the lower links of that chain?

Therefore the best leaders have started low. They have learned how to *obey* directions before they are entrusted with the responsibility of *giving* them.

For example, early in his ministry Jesus chose twelve men who would lead the church when he was gone. He called them "apostles"—a word signifying "those authorized to act in the sender's name." They were not volunteers but draftees, and Jesus was going to send them out to preach and cast out demons. So this was a responsible calling. But what was the first part of their job? Mark 3:14 reads, "He appointed twelve—naming them apostles—that they might be with him...." The first part of their call as leaders was simply to be with Jesus. They watched him, listened to him, observed his character, and learned his objectives and principles of ministry. Yes, they were going to lead, and in time they did. But their first task was to follow. Good Christian leaders were once good followers.

Joshua was a great leader. He commanded Israel in her campaign to conquer Canaan. But for long years before he served as leader he served as follower and aide to Moses.[1] Before becoming a great prophet Elisha "poured water on the hands of Elijah."[2] Timothy was fully aware of Paul's teaching and doctrine,[3] and had served the

[1]Ex 24:13; 33:11; Num 11:28; Jos 1:1.

[2]2 Ki 3:11.

[3]2 Tim 3:10-11.

great apostle as a son with his father.[4] That is why later he led so well.

Not only were biblical leaders good followers *before* they started to lead, they continued to be good followers *while* they led. Paul urged the Corinthians, "Follow my example, as I follow the example of Christ."[5] Paul was still following—day by day and hour by hour—the example of Christ. His following made him an effective leader. The minute we stop *following* Christ is the minute we stop effectively *leading*.

So good biblical leaders are good followers, as have been many secular business, political, and military chiefs.

How can we apply this principle? First, we ourselves should not rush into leadership. A wiser attitude is that of Solomon and Jeremiah.[6] Leadership is a great responsibility; those who point the way (and especially teach) will be judged more strictly.[7]

Second, we should therefore devote much energy to our own discipleship, preparation, and learning. Time spent in Bible study—both formal and personal—is an investment, not a luxury. "It is not good to have zeal without knowledge, nor to be hasty and miss the way."[8] Zeal without knowledge was Israel's problem; hence she missed her messiah.[9] True prophets excoriated their false counterparts who rushed to speak without stopping to hear Yahweh's council.[10] A hurried leader may plunge into battle only to discover that he has engaged the wrong enemy or is using inappropriate weapons and tactics. Further, a theological degree does not mean that its owner can relax and coast through serving and sermonizing. Following, learning, and growing are lifelong pursuits; it may thus be wise to choose a ministry where peers can continuously evaluate and correct us.

[4]Phil 2:22.

[5]1 Cor 11:1.

[6]1 Ki 3:7; Jer 1:6.

[7]Jas 3:1.

[8]Prov 19:2.

[9]Rom 10:2.

[10]e.g., Jer 23:16–32.

Third, we should not be too quick to promote others to leadership. Hence the warnings in the pastorals against new converts and hasty ordinations.[11] In our rapidly-growing Cambodian churches and NGOs we scrounge and pray for leaders, but before we appoint them let us be sure they are true followers of Jesus Christ and accomplished in whatever technical and people skills the position we envision requires. Ecclesiastical and organizational horror stories abound of aspiring young leaders who have assumed major responsibilities too quickly, only to succumb to pride, corruption, or temptation. "They must first be tested"[12] is a wise caution for all kinds of positions. It is not enough that a candidate be enthusiastic, personable, liked, and able to repeat catch phrases. We must also determine whether he or she is a skilled and proven follower.

## A Good Leader Serves

There has never been a stronger or more deserving leader than Jesus. He was always right. He is Immanuel—God with us—and hence savior and lord. He is worthy not only of obedience but also of worship, which we should render to no other. But *how* did Jesus lead? Did he parade his authority, forcing his subordinates to bow the knee and pamper him? Did he use his position to enrich himself? No. Jesus' leadership was characterized by service. In a key verse of Mark Jesus explained why he had come—"not ... to be served, but to serve, and to give his life as a ransom for many."[13] Jesus was and is the world's greatest and most deserving leader. But as leader he came to serve, and to serve in the most profound way—by giving his life. If we wish to follow his example, then we will lead by serving, not by exploiting our positions to make ourselves comfortable, powerful, or rich.

A leader who ignores this counsel may find himself without followers. That is what happened to Rehoboam. At the beginning of his reign Rehoboam's prospective subjects petitioned him for relief

---

[11]1 Tim 3:6; 5:22.

[12]1 Tim 3:10.

[13]Mk 10:45.

from the heavy tax burden his father had imposed. The elders counseled, "If today you will be a servant to these people and serve them and give them a favorable answer, they will always be your servants." But Rehoboam rejected that sage advice and heeded the young men who urged that he show the people who was boss. The result? He lost ten of the twelve tribes he should have ruled.[14] Heavy-handed leaders tend to lose their followers—certainly in their affections, often in their allegiance.

Paul, by contrast, led by serving, as did his Lord whom he followed. Instead of polishing his own reputation vis-à-vis Apollos he taught that both were merely servants, of no importance when compared with God, and not competing with but rather complementing one another.[15] As a servant he was willing to suffer for the church, which he often did.[16] In this way he became a great leader whom Christians still respect and follow today.

Similarly, if we today wish to be remembered as Pauls and not as Rehoboams, we must recall and practice Jesus' advice—"If anyone wants to be first, he must be the very last, and the servant of all."[17]

### A Good Leader Builds

Some leaders think that the best way they can use their position is to secure their own wealth, power, and reputation. Their job is certainly not to help others. They are interested in the welfare or advancement of constituents and subordinates only to the extent that these are encouraged to continue to support them. If another leader in the organization begins to rise in power or popularity, he or she is considered a threat that must be put down.

Leaders who think this way are consequently afraid of allowing those who work under them to succeed. They don't want associates to acquire skills they themselves lack, or to be seen too

[14] 1 Ki 12:1–19.

[15] 1 Cor 3:5–8.

[16] 2 Cor 3:8–10; 6:3–10; Phil 2:17; Col 1:24–25; etc.

[17] Mark 9:35.

often in highly visible ministries. They fear that if others gain too many skills or too much recognition, their own status will be threatened. Nervous self-seekers then harass, publicly disgrace, demote, or fire rising stars. They may assign them to peripheral posts, or to jobs impossible to accomplish and certain to lead to criticism. Some sink to making scandalous innuendos or threats, or to inflicting physical harm.

By contrast, great leaders build their subordinates up and rejoice when they succeed.

Ephesians 4:11–16 tells why Christ gives spiritual gifts to individuals. It is not to make the recipients proud or powerful. No, spiritual gifts are given "to prepare God's people for works of service" (v. 12). My giftedness is not so that people will think I am great, but to equip me to help others so that they will be able to serve. A good leader does not try to do everything himself so that he keeps all the power and no one else develops ministry skills. Rather, a good leader works to build others up—to empower and enable them—and rejoices when *they* succeed. It is only when *everybody* in the church is working—not just the pastor—that "the body of Christ [is] built up" and "we all reach unity in the faith and in the knowledge of the Son of God and become mature" (v. 13).

So a good church leader continually asks himself, "Am I trying to do everything myself and to limit the opportunities of others so that all power remains with me? Or am I working to build others up so that *they also* may succeed?" Do we show others how to study the Bible for themselves? Do we show others how to care for the church's finances so that they are wisely spent and accounted for in an honest, open manner? Do we teach others how to teach and preach, and give them opportunities to do so? These are things that good leaders do—they *build others up* so that they can succeed.

Some leaders are afraid to do this because they fear that in time their disciples will do better than they themselves, and hence become more powerful and better known. It is true; that may happen. But that is O.K. The disciples of John the Baptist became jealous for John when Jesus started his ministry, because people were leaving John and following Jesus. But John replied, "He must become greater;

I must become less."[18] Andrew brought his brother Simon Peter to Jesus,[19] and soon Peter was better known than Andrew. When Saul of Tarsus came to faith, the early church thought his conversion was a ruse. But Barnabas believed Saul and introduced him to the church.[20] Before long Saul—the Apostle Paul—became stronger and better known than Barnabas. But if our love is for Jesus, and our deepest desire that he be honored and known, then it should be O.K. with us if God uses those we train even more than he uses us. After all, ministry is about the success of the church and the honor of Jesus' name, not our success and the honor of our name.

In the nineteenth century a nervous Sunday School teacher in the United States visited a shoe store to share the gospel with one of its salesmen. Most of us do not know the name of that Sunday School teacher, but many have heard of the shoe salesman. His name was Dwight L. Moody, and God used him as a great evangelist. Today a school, a radio ministry, and a publishing house bear his name. The follower surpassed the leader, but I'm sure that nervous Sunday School teacher thinks that is just fine.

We must conclude, therefore, that a good Christian leader is someone who does not focus on protecting or promoting himself. Rather he edifies others so that *they* can succeed.

### A Good Leader Leads

So far we have said that a leader is someone who follows, who serves, and who builds others. If that were all that the Bible says on this subject, we might conclude that a leader should never be strong or decisive. If a leader is a good follower, and one who serves and builds up others, then is it ever right that he should stand at the front and give bold, firm directions?

The answer to that question is an enthusiastic "Yes!" While it is true that a Christian leader, like Jesus, seeks to serve rather than be served, and, like Paul, to build up others' ministries rather than

---

[18]John 3:30.

[19]John 1:40–41.

[20]Acts 9:26–28.

focusing attention on himself, that does not mean that he does not act decisively. On the contrary, by definition a leader is someone who *leads!* He takes the initiative, points the way, and warns of dangers. He does not sit back and wait for others, or even for God, to do something. A good leader *serves* by *leading*.

Sometimes people bear the *title* of leader, but leave the actual *work* of leading to others. For example, Saul was Israel's first king. As king he was Israel's leader. So when the giant Goliath challenged Israel to battle, Saul should have been the one to accept that challenge. Rather than sitting in his tent with the title of leader, he should have stood up in God's strength and *led*. Instead it was the shepherd lad David who, although he had no *title*, stood strong in God's strength and *led* Israel that fateful day against her enemy. It was Saul's own fault that when the army returned from battle the women who came out to meet them celebrated David more than they did the king by singing, "Saul has slain his thousands, and David his ten thousands!"

This was not the first time that Saul, who bore the *title* of king and leader, failed to actually *lead*. In 1 Samuel 14:1 Saul's son Jonathan took the initiative to trust God and *lead* in an attack against Israel's enemies. Verse 2 shows us what the king was doing—sitting under a pomegranate tree with his six hundred men. Later in chapter 15 he let the people talk him into disobeying the LORD's command—he didn't take a stand and *lead* against their wishes. It is no wonder then that Saul's kingship did not last, and God found someone else who would lead his people as he should.

Leading means we will sometimes have to take a strong stand, and sometimes a lonely stand. Sometimes others may be afraid or asleep or ignorant, and be walking down the wrong path. That is when a leader stands tall and speaks strongly about what should be done, even if what he advocates is unpopular. He does this not to build his own status, but for the sake of the truth. Elijah was a strong leader who stood alone against Jezebel's four hundred prophets of Baal. He did this not for himself but for the sake of the truth. Jeremiah and other Old Testament prophets often took unpopular stands. Paul opposed Peter to his face in Galatians 2. He did this not to enhance his power or reputation at Peter's expense, but simply

because Peter was wrong. Peter needed to be corrected before he led a large segment of the church into error.

So even though a good leader first follows, and does not deprive others of training or opportunities in order to keep everybody's attention on himself, at times he serves them best by taking a strong stand to show them the way to go. A good leader *serves* by *leading*.

Because a leader has to actually *lead* his people, he must first be certain of the direction to take. That is why he must first have been a good follower. Leaders have to lead, but if they are unsure where they are going because they are not closely following the Lord, they may lead their flocks into disaster. That is what Jesus was talking about when he said of the Pharisees, "Leave them; they are blind guides. If a blind man leads a blind man, both will fall into a pit."[21] The Pharisees were not following the Lord. So although they were doing their job as leaders to lead, they did not know where they should be going and led their flocks into a pit. A good leader knows the way he should be going, and then boldly strikes out and leads his people down that path.

## A Good Leader Passes On the Baton

Footraces are popular athletic events. Runners crouch behind the starting line, and when the gun is fired all take off for the finish line. Many races are individual events. Each racer in an individual event is his own "team"—how she does and whether she wins depends solely upon herself. She has no teammates. But other races are relays. A relay team may consist of four members. As the race is ready to start, an official gives the first member of each team a small stick or baton to carry. When the gun is fired, this first member runs around the track carrying this baton. Then as each returns to the starting point the second member of his team is waiting. This second member starts to run alongside the first, and the first hands over the baton to him. The first member, having completed his lap, drops out and the second carries the baton and runs around the track. As he completes his circuit and approaches the starting line the third member

[21]Matt 15:14.

of the team is waiting. Again the baton must be handed off, and the second retires and the third takes over. This process continues until all team members have run with the baton around the course. The winner of the race is not any *individual*, but the *team* that runs together the best and can execute smooth and efficient handovers of the baton. If any individual team member does not work well with the others—racing alongside the one in front to take the baton from him, and making sure he firmly places the baton in the grasp of the one who follows him—his team will not win. Even if that individual runs the fastest lap of all the runners in that race, if he does not take and hand over the baton efficiently, his team will lose. A relay race is not about individual performance but about team performance.

Christian leadership is like that. We are not in leadership to draw attention to how well *we* lead, or evangelize, or teach, or preach. We are part of a team where we are called upon to do our part as best we can, and then hand on the baton to someone else.

Christian ministry started with Jesus. When the time came for him to finish his ministry by dying for us, being raised, and returning to heaven, he passed on the baton of ministry to his apostles. He told them, "Now I am going to him who sent me, . . . [and] you are filled with grief. But I tell you the truth: It is for your good that I am going away. Unless I go away, the Counselor will not come to you; but if I go, I will send him to you."[22] Later he said, "As the Father has sent me, I am sending you."[23] Jesus was leaving; he was handing over his ministry to them; and he would send the Holy Spirit to enable them to fulfill it.

So the apostles took over where Jesus personally had stopped. The New Testament talks about Jesus' apostles laying the foundation of the church.[24] But the apostles did not minister forever, though some of them did well and their ministries started the church. The time came when they had to hand over their work to others. Paul, for example, was personally commissioned by Christ, did his job well,

---

[22]John 16:5–7.

[23]John 20:21.

[24]1 Cor 3:10–12; Eph 2:2; Rev 21:14.

and then handed over his work to Timothy. Paul gave important instructions to his follower by commanding, "And the things you have heard me say in the presence of many witnesses entrust to reliable men who will also be qualified to teach others."[25] Timothy was to take the baton from Paul, run his own lap, and then pass the baton on "to reliable men" who would run their laps and then "be qualified to teach others." Christian ministry is not an individual race, designed to draw attention to individual stars or heros. It is a relay race where we take over message and commission first given to others, and after running our brief lap find someone to whom we can entrust the work.

As leaders, then, we should be always on the lookout for a few good people with whom we can invest extra energy so that some day they can take over smoothly and run well. Just as a relay race cannot be won if one team drops the baton or does not hand it over smoothly, so our Christian ministries will suffer if we do not have people trained and ready to take over when we move on.

Because Jesus knew he would soon be crucified and leave this earth, he spent much time in the latter part of his ministry training his disciples. After Peter came to the conclusion that Jesus was Israel's messiah, Jesus "began to explain to his disciples that he must go to Jerusalem and suffer. . . ."[26] It seems he spent more time with them and a smaller percentage with the crowds. Instead of doing all the preaching himself he sent out the Twelve, and later seventy others, to preach and teach. Rather than standing up himself and teaching, he gave others the opportunity to learn the skill, even though he could have done it better. He was preparing them to take the baton.

So if we are to be good leaders, not only must we do our own job well, we must constantly be training another to take our place. Are you doing this? Do you have someone with whom you meet for study and prayer? Do you take others with you as you minister, so that they can observe . . . and then share . . . and then take over?

---

[25]2 Tim 2:2.

[26]Matt 16:21.

សំណុំឯកសារ ៤/១ (មករា ២០០៣): ១១៧-១៣៦



# លក្ខណៈសម្បត្តិរបស់អ្នកដឹកនាំ

*រ៉ាស់សែល បាទទើស*

មេដឹកនាំខ្មែរក្រហមប៉ុលពត អ្នកម្តាយទេរីសារ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន លោកប្រមុខរដ្ឋ ចេង ហេង ព្រះបរមគ្រូពុទ្ធនិយម គូតាម៉ា ប៊ូដា មេភារវករ អូសាម៉ា ប៊ីនឡាដិន ។ តើលក្ខណៈរួមដូចគ្នាអ្វីទៅដែលអស់លោកទាំងនោះមាន?

ពួកលោកជាអ្នកដឹកនាំ ។ ទោះជាល្អ ឬអាក្រក់ ដោយចេតនាថ្លៃថ្នូរ ឬមិនថ្លៃថ្នូរ គឺពួកលោកបានឈរនៅខាងមុខ ហើយបានប្រមូលផ្តុំជនរួមជាតិឲ្យដើរតាមខ្លួន ។ វាសនាមនុស្សរាប់លាននាក់មានលក្ខណៈបែបណានោះ គឺដោយសារតែអស់លោកប៉ុន្មាននាក់នេះឯង ។

អ្នកដឹកនាំដែលល្អ មិនអាចកំណត់តំលៃបានទេ ។ តើមនុស្សនឹងទៅជាយ៉ាងណាប្រសិនបើគេគ្មានការបំផុសគំនិត សេចក្តីក្លាហាន ការស្វែងយល់ និងប្រាជ្ញា? តើសេចក្តីសង្ឃឹមរបស់គេនឹងមិនរសាយបាត់ទៅហើយឬ? ផ្ទុយទៅវិញ អ្នកដឹកនាំអាក្រក់អាចបណ្តាលឲ្យមានទុក្ខសោកនិយាយមិនអស់ ឬធ្វើឲ្យមានសេចក្តីខ្មាសដល់អ្នកដើរតាម ។ បើ

សិនជាឲ្យឧទាហរណ៍វិញគឺមានច្រើនខ្លាំងណាស់ ហើយធ្វើឲ្យឈឺចាប់ក្នុងការនិទានចេញទៀតផង។

តើត្រូវធ្វើយ៉ាងដូចម្ដេច ដើម្បីឲ្យយើងរកឃើញថាអ្នកដឹកនាំមួយល្អ ហើយមួយទៀតមិនល្អបាន? តើយើងអាចក្លាយទៅជាអ្នកដឹកនាំល្អបានដោយរបៀបណា? ក្នុងប្រទេសកម្ពុជានៅពេលដែលក្រុមជំនុំកំពុងតែរីកចំរើនយ៉ាងលឿនបំផុតនោះ បន្ទុករបស់យើងគឺ ត្រូវហ្វឹកហ្វឺនអ្នកដឹកនាំជំនាន់ថ្មី។ តើទិសដៅរបស់យើងសំដៅទៅលើអ្វី? តើគុណភាពអ្វីទៅដែលយើងត្រូវស្វែងរកឲ្យឃើញ និងបង្កើតឲ្យមានឡើង?

អត្ថបទនេះមិនអាចឆ្លើយនូវសំនួរទាំងនេះឲ្យពេញលេញបានទេ ។ ប៉ុន្តែខ្ញុំសូមផ្ដល់នូវលក្ខណៈសម្បត្តិប្រាំយ៉ាងរបស់អ្នកចាប់ផ្ដើម ។ លក្ខណៈសម្បត្តិទាំងនេះ អាចប្រើជាប្រយោជន៍ដល់អ្នកដឹកនាំច្រើនប្រភេទ។ ប៉ុន្តែជាពិសេសនៅក្នុងក្រុមជំនុំ អ្នកដឹកនាំល្អគឺជាអ្នកដែលៈ

- ដើរតាម
- បំរើ
- កសាង
- នាំមុខ
- ហុចកំណាត់ឈើរត់ប្រណាំងបន្តទៅឲ្យអ្នកដទៃ

## អ្នកដឹកនាំល្អគឺជាអ្នកដើរតាម

វាហាក់បីដូចជាផ្ទុយគ្នាក្នុងការនិយាយថាអ្នកដឹកនាំជាអ្នកដើរតាមទៅវិញ ។ យើងតែងតែពុជារឿយៗមកថាអ្នកដឹកនាំគឺជាអ្នកឈរនៅខាងមុខបង្ហាញផ្លូវ និងចេញបញ្ជាផ្សេងៗ ប៉ុន្តែអ្នកដឹកនាំដែលល្អបំផុតគឺជា អ្នកចាប់ផ្ដើមចេញមកពីអ្នកដើរតាមយ៉ាងល្អជាមុនសិន ។ តើអ្នក

ដឹកនាំដឹងយ៉ាងណាបានអំពីរបៀបបណ្តុញនៃការងារ លុះត្រាតែគាត់មានបទពិសោធន៍នៅក្នុងឋានៈទាបនៃបណ្តាញការងារនោះជាមុនសិន ។

ដូច្នេះអ្នកដឹកនាំដែលប្រសើរបំផុត គឺចាប់ផ្តើមពីទាបមកមុន ។ ពួកលោកធ្លាប់រៀនស្តាប់បង្គាប់តាមការណែនាំ មុនដែលពួកលោកបានទទួលការប្រគល់ការទទួលខុសត្រូវឲ្យធ្វើ ។

ឧទាហរណ៍ កាលទើបតែចាប់ផ្តើមព័ន្ធកិច្ចដំបូង ព្រះយេស៊ូជ្រើសរើសមនុស្ស១២នាក់ ដែលនឹងដឹកនាំក្រុមជំនុំនៅពេលដែលទ្រង់ចាកចេញពីពួកគេ ។ ទ្រង់ហៅពួកគេថា "សាវ័ក" ដែលមានន័យថា "អ្នកដែលបានទទួលសិទ្ធអំណាច ឲ្យធ្វើសកម្មភាពអ្វីមួយបានក្នុងឈ្មោះអ្នកដែលបញ្ជូនមក" ។ ពួកគេមិនមែនស្ម័គ្រចិត្តទេ ប៉ុន្តែជាកូនកំណែនដែលព្រះអង្គបានជ្រើសរើស ហើយព្រះអង្គក៏បានបញ្ជូនពួកគេឲ្យចេញទៅប្រកាសដំណឹងល្អ និងដេញអារក្ស។ នេះហើយ គឺជាការទទួលខុសត្រូវចំពោះការត្រាស់ហៅ ។ ប៉ុន្តែផ្នែកដំបូងនៃកិច្ចការរបស់ពួកគេមានអ្វីខ្លះ? ម៉ាកុស ៣:១៤ បានចែងថា "ទ្រង់បានជ្រើសរើស១២នាក់ ឲ្យឈ្មោះពួកគេថាសាវ័ក ដើម្បីឲ្យពួកគេនៅជាមួយព្រះអង្គ..." ។ ដើម្បីឲ្យពួកគេទៅជាអ្នកដឹកនាំ ព្រះអង្គត្រាស់ហៅពួកគេឲ្យគ្រាន់តែនៅជាមួយព្រះអង្គសិន ។ ពួកគេមើលឃើញព្រះអង្គ ស្តាប់ព្រះអង្គ សង្កេតមើលលក្ខណៈសម្បត្តិរបស់ព្រះអង្គ ហើយរៀនពីគោលបំណងរបស់ព្រះអង្គ និងគោលការណ៍នៃព័ន្ធកិច្ច ។ ពិតប្រាកដពួកគេនឹងដឹកនាំ ហើយដល់ពេលកំណត់ ពួកគេក៏បានដឹកនាំមែន ។ ប៉ុន្តែភារកិច្ចដំបូងរបស់ពួកគេ គឺដើរតាម ។ អ្នកដឹកនាំគ្រីស្តបរិស័ទដែលល្អគឺជាអ្នកដែលធ្លាប់ដើរតាមបានយ៉ាងល្អ ។

យ៉ូស្វេគឺជាអ្នកដឹកនាំដ៏ល្អម្នាក់ ។ គាត់បានបញ្ជាពួកអ៊ីស្រាអែលនៅក្នុងសមរភូមិឲ្យយកឈ្នះលើទឹកដីកាណាន់ ។ ប៉ុន្តែជាច្រើនឆ្នាំមុនដែល គាត់បំរើជាអ្នកដឹកនាំ គាត់បានបំរើជាអ្នកដើរតាម និងជាអ្នកជំនួយ

ការដល់ម៉ូសេ[1] ។ អេលីសេមុនពេលដែលគាត់ក្លាយជាហោរាដ៏អស្ចារ្យម្នាក់ "គាត់បានចាក់ទឹកទៅលើដៃរបស់អេលីយ៉ា"[2] ។ ធីម៉ូថេបានដឹងយ៉ាងច្បាស់ពីសេចក្តីបង្រៀន និងគោលលទ្ធិរបស់ប៉ុល[3] ហើយបានបំរើសាវ័កដ៏អស្ចារ្យទុកជាកូន និងឪពុក[4] ។ ដូច្នេះហើយបានជាបន្ទាប់មកគាត់ដឹកនាំបានយ៉ាងល្អ ។

អ្នកដឹកនាំតាមបែបព្រះគម្ពីរមិនមែនគ្រាន់តែជាអ្នកដើរតាមល្អមុនពេលចាប់ផ្តើមដឹកនាំប៉ុណ្ណោះទេ គឺពួកគេនៅតែបន្តជាអ្នកដើរតាមល្អជានិច្ច ក្នុងខណៈពេលដែលគេកំពុងតែធ្វើជាអ្នកដឹកនាំផងដែរ ។ លោកប៉ុល បានជំរុញទឹកចិត្តពួកកូរិនថូសថា "ចូរធ្វើតាមគំរូខ្ញុំ ដូចជាខ្ញុំធ្វើតាមគំរូនៃព្រះគ្រីស្ទដែរ"[5] ។ លោកប៉ុល នៅតែដើរតាមគំរូព្រះគ្រីស្ទជានិច្ចជារៀងរាល់ថ្ងៃ និងជារៀងរាល់ម៉ោង ។ ការដែលគាត់ដាក់ចិត្តធ្វើជាអ្នកដើរតាមគំរូព្រះគ្រីស្ទធ្វើឲ្យគាត់ក្លាយទៅជាអ្នកដឹកនាំដ៏មានប្រសិទ្ធភាព ។ នាទីណាដែលយើងឈប់ដើរតាមព្រះគ្រីស្ទ នាទីនោះគឺជាទីបញ្ចប់នៃការក្លាយជាអ្នកដឹកនាំល្អហើយ ។

ដូច្នេះអ្នកដឹកនាំល្អតាមបែបព្រះគម្ពីរ គឺជាអ្នកដើតាមដ៏ល្អដែរ ដូចគ្នានឹងថៅកែជំនួញ អ្នកដឹកនាំនយោបាយ និងមេដឹកនាំលោកីយ៍ផ្សេងៗជាច្រើន ដែលយើងបានឆ្លងកាត់រួចមកហើយ ។

តើយើងអនុវត្តគោលការណ៍នេះយ៉ាងដូចម្តេចបាន?

---

[1] *និក្ខមនំ ២៤:១៣; ៣៣:១១; ជនគណនា ១១:២៨; យ៉ូស្វេ ១:១*

[2] *ពង្សាវតាក្សត្រ ៣:១១*

[3] *២ធីម៉ូថេ ៣:១០-១១*

[4] *ភីលីព ២:២២*

[5] *១កូរិនថូស ១១:១*

<u>ទីមួយ</u>: ខ្លួនយើងផ្ទាល់ មិនត្រូវប្រញាប់ចូលទៅក្នុងថ្នាក់ដឹកនាំភ្លាមៗនោះឡើយ ។ អត្តចរិតប្រកបដោយប្រាជ្ញា គឺជាអត្តចរិតដូចជាសាឡូម៉ូន និងយេរេមា[6] ។ ការដឹកនាំគឺជាការទទួលខុសត្រូវដ៏ធំធេងមួយអ្នកចង្អុលផ្លូវ (ជាពិសេសអ្នកបង្រៀន) ព្រោះអ្នកបង្រៀនគេនឹងត្រូវទទួលទោសខ្លាំងជាងគេ[7] ។

<u>ទីពីរ</u>: យើងត្រូវតែ ចំណាយកំលាំងយើងយ៉ាងខ្លាំងទៅក្នុងការបង្កើតសិស្ស ការរៀបចំ និងការរៀនសូត្រទៅលើខ្លួនយើង ។ ការចំណាយពេលសិក្សាព្រះគម្ពីររួមគ្នា និងផ្ទាល់ខ្លួន គឺជាការបណ្តាក់ទុនមួយយ៉ាងសំខាន់ មិនមែនជាភាពស្រណុកស្រួលនោះទេ ។ "ភាពឆេះឆួល ដោយគ្មានគំនិះ មិនមែនជាការល្អឡើយ រីឯការខំទាំងញាក់ញ័រក៏ដូចតែគ្នា"[8] ។ ភាពឆេះឆួលដោយគ្មានគំនិះ គឺជាបញ្ហារបស់អ៊ីស្រាអែល ។ ហេតុដូច្នេះហើយបានជាពួកគេមិនស្គាល់ព្រះមែស៊ីរបស់ខ្លួន[9] ។ ហោរាពិតប្រាកដស្ដីបន្ទោសដល់ហោរាក្លែងក្លាយ ដោយព្រោះតែពួកគេប្រញាប់ក្នុងការនិយាយ ដោយមិនបានស្តាប់ការប្រឹក្សាមកពីព្រះយេហូវ៉ាជាមុន[10] ។ អ្នកដឹកនាំដែលញាក់ញ័ររហ័សពេក អាចបោះពួយយ៉ាងខ្លាំងចូលទៅក្នុងសង្គ្រាម រួចហើយទើបដឹងថា គេជួបនឹងសត្រូវ ហើយក៏ចាប់ផ្តើមប្រើអាវុធ និងយុទ្ធសាស្ត្រ ដោយមិនសមទៅតាមកាលៈទេសៈ ។ ជាងនេះទៅទៀត សញ្ញាប័ត្រទេវវិទ្យាមិនមែនមានន័យថា ម្ចាស់សញ្ញាប័ត្រនោះអាចសំរាក និងបណ្តែតបណ្តោយតាមរយៈការបំរើ និងការរៀបចំ

---

[6] *១ពង្សាវតាក្សត្រ ៣:៧; យេរេមា ១:៦*

[7] *យ៉ាកុប ៣:១*

[8] *សុភាសិត ១៩:២*

[9] *រ៉ូម ១០:២*

[10] *ឧទាហរណ៍: យេរេមា ២៣:១៦:៣២*

សេចក្ដីអធិប្បាយប៉ុណ្ណោះនោះទេ ។ ការធ្វើតាម ការរៀនសូត្រ និង ភាពលូតលាស់ គឺជាការខិតខំប្រឹងប្រែងមួយជីវិត ។ ជាការឈ្លាសវៃ កាលណាយើងជ្រើសរើសព័ន្ធកិច្ចគ្រីស្ទជួយវាយតំលៃ និងការកែតំរង់ ។

<u>ទីបី</u>: យើងមិនត្រូវជ្រើសរើសអ្នកណាចូលទៅក្នុងថ្នាក់ដឹកនាំលឿនពេកទេ ។ ដូច្នេះហើយការដាស់តឿននៅក្នុងការដឹកនាំជាគ្រូគង្វាល គឺប្រឆាំងទៅនឹងអ្នកទើបតែជឿថ្មី និងភាពប្រញាប់ប្រញាល់នៃការចាក់ប្រេងតាំងឲ្យ[11] ។ នៅក្នុងការរីកចំរើនយ៉ាងឆាប់រហ័សរបស់យើង ក្រុមជំនុំ និង អង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ត្រូវតែទូលអង្វរ និងអធិស្ឋានសំរាប់អ្នកដឹកនាំជាមុន មុននឹងយើងតែងតាំងពួកគេឡើងឲ្យដឹកនាំ ដើម្បីឲ្យយើងដឹងពិតប្រាកដថា ពួកគេពិតជាអ្នកដើរតាមព្រះយេស៊ូដ៏ពិតប្រាកដមែន និងមានគ្រប់ទាំងបច្ចេកទេស និងជំនាញនៅក្នុងឋានៈ ដែលតំរូវឲ្យពួកគេធ្វើ។ រឿងដែលគួរឲ្យសោកស្ដាយរបស់ក្រុមជំនុំ និងអង្គការផ្សេងៗនោះគឺកើតមានឡើងចំពោះអ្នកដឹកនាំក្មេងខ្ចី ដែលបានទទួលនូវការទទួលខុសត្រូវក្នុងផ្នែកសំខាន់ៗឆាប់រហ័សពេក ធ្វើឲ្យពួកគេសម្បូរណ៍ទៅដោយមហិមា ដែលនាំឲ្យគេបង្អោនទៅរកភាពអំនួត ពុករលួយ ឬសេចក្ដីល្បួង ។ “ពួកគេត្រូវតែទទួលការសាកល្បងជាមុនសិន”[12] ព្រោះវាជាការប្រុងប្រយ័ត្នដ៏ឈ្លាសវៃ សំរាប់គ្រប់ទាំងប្រភេទនៃឋានៈណាក៏ដោយ ។ វាមិនគ្រប់គ្រាន់ទេ ប្រសិនបើបេក្ខជនគ្រាន់តែមានចិត្តឆេះ ឆួល លក្ខណៈសម្បត្តិសមរម្យ ចូលចិត្ត ហើយមានសមត្ថភាពទន្ទេញតាមចាំនោះ ។ យើងត្រូវស្វែងយល់ឲ្យដឹងថា តើគាត់មានអ្នកដើរតាមមែនដែរឬទេ ។

---

[11] *១ធីម៉ូថេ ៣:៦; ៥:២២*

[12] *១ធីម៉ូថេ ៣:១០*

## អ្នកដឹកនាំល្អគឺជាអ្នកបំរើ

មិនដែលមានអ្នកដឹកនាំណាមួយខ្លាំងក្លា ឬគួរឲ្យសរសើរ លើសព្រះយេស៊ូឡើយ ។ ទ្រង់តែងតែត្រឹមត្រូវជានិច្ច ។ ទ្រង់ គឺជាអ៊ីម៉ាញូអែល "ព្រះគង់ជាមួយយើង" ហើយជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់ ។ ទ្រង់មិនមែនគ្រាន់តែជាព្រះដែលគួរឲ្យយើងស្ដាប់បង្គាប់ តែប៉ុណ្ណោះទេ ប៉ុន្តែទ្រង់គួរឲ្យយើងថ្វាយបង្គំទៀតផង យើងមិនគួរទៅថ្វាយបង្គំព្រះឯណាផ្សេងទៀតក្រៅពីព្រះអង្គឡើយ ។ បើសិនជាដូច្នេះមែនតើព្រះយេស៊ូដឹកនាំដោយរបៀបណា? តើទ្រង់សំដែងអំណាចរបស់ទ្រង់ ដោយបង្ខំអ្នកដែលនៅក្រោមព្រះអង្គ ឲ្យក្រាបដោយលុតជង្គង់ ហើយញាប់ញ័រនៅចំពោះទ្រង់ឬ? តើទ្រង់ប្រើឋានៈរបស់ព្រះអង្គដើម្បី លើកអង្គទ្រង់ឡើងមែនទេ? មិនមែនដូច្នេះឡើយ ។ ការដឹកនាំរបស់ព្រះយេស៊ូ បានបង្ហាញតាមរយៈការបំរើ ។ នៅក្នុងខគម្ពីររបស់ម៉ាកុស ព្រះយេស៊ូបានពន្យល់ហេតុអ្វីបានជាទ្រង់ត្រូវមក "មិនមែន... ដើម្បីឲ្យគេបំរើ ប៉ុន្តែដើម្បីបំរើគេវិញ ហើយនឹងលះបង់ជីវិតខ្លួនទុកជាថ្លៃលោះមនុស្សជាច្រើនផង"[១៣] ។ ព្រះយេស៊ូជាអ្នកដឹកនាំដ៏អស្ចារ្យ និងគួរសរសើរបំផុត តាំងតែពីមុនរហូតដល់សព្វថ្ងៃនេះ ។ ប៉ុន្តែក្នុងនាមជាអ្នកដឹកនាំ ទ្រង់យាងមកដើម្បីបំរើ ហើយបំរើនៅក្នុងផ្លូវដ៏អស្ចារ្យបំផុត ដោយការប្រគល់នូវជីវិតរបស់ព្រះអង្គ ។ ប្រសិនបើយើងប្រាថ្នាចង់ធ្វើតាមគំរូរបស់ព្រះអង្គនោះ យើងត្រូវដឹកនាំដោយការបំរើ មិនមែនប្រើឋានៈរបស់យើង ដើម្បីក្រេបជញ្ជក់យកផលប្រយោជន៍ពីអ្នកដទៃឡើយ ដើម្បីឲ្យមានភាពសុខស្រួល អំណាច ឬក្លាយជាអ្នកមានដល់ខ្លួនឯងតែប៉ុណ្ណោះនោះឡើយ ។

---

[13] ម៉ាកុស ១០:៤៥

អ្នកដឹកនាំណាដែលបដិសេធការប្រឹក្សានេះ នោះប្រហែលជារកឃើញថា ខ្លួនគេគ្មានអ្នកដើរតាមឡើយ ។ នេះឯងជាការដែលកើតឡើងដល់រេហូបោម ។ នៅឯការចាប់ផ្តើមគ្រងរាជ្យដំបូង អ្នកដែលសង្ឃឹមពីរេហូបោម គឺចង់ឲ្យទ្រង់សម្រាលពន្ធដាដ៏ធ្ងន់ធ្ងរដែលបិតារបស់ទ្រង់បានដាក់ដល់ប្រជារាស្ត្រ ។ ពួកចាស់ទុំបានជួយប្រឹក្សាទ្រង់ថា "នៅថ្ងៃនេះ បើទ្រង់សព្វព្រះទ័យ និងធ្វើតាមចិត្តប្រជាជនទាំងឡាយ ហើយយកចិត្តគេដោយឆ្លើយនឹងគេ ជាពាក្យផ្អែមពិរោះ នោះគេនឹងនៅជាបាវបំរើទ្រង់ជាដរាបទៅ" ។ ប៉ុន្តែរេហូបោមបដិសេធគំនិតនៃពួកចាស់ទុំទាំងនោះ ហើយបែរទៅប្រឹក្សាជាមួយមនុស្សស្រករនឹងទ្រង់វិញ ដែលឲ្យគំនិតថា ទ្រង់គួរបង្ហាញឲ្យពួកគេដឹងថាទ្រង់ជាចៅហ្វាយពួកគេ ។ លទ្ធផល គឺទ្រង់បាត់បង់ពូជអំបូរទាំង១២ ដែលទ្រង់ត្រូវគ្រប់គ្រងលើពួកគេ[១៤] ។ អ្នកដឹកនាំក្បាលរឹងតែងតែបាត់បង់អ្នកដើរតាមខ្លួន ។ ពិតប្រាកដហើយនៅក្នុងការថ្នាក់ថ្នមរបស់ពួកគេ គឺតែងតែមានភក្តីភាពនៅក្នុងពួកគេ ។

ផ្ទុយទៅវិញលោកប៉ុល ដឹកនាំក្នុងភាពជាអ្នកបំរើ ដូចដែលព្រះអម្ចាស់របស់គាត់បានធ្វើ និងជាអ្នកដែលគាត់បានដើរតាម ។ ជំនួសឲ្យការជុសខាត់កេរ្តិ៍ឈ្មោះរបស់ខ្លួនឲ្យកាន់តែភ្លឺឡើង បើប្រៀបធៀបទៅនឹងអាប៉ូឡូស គាត់បានបង្រៀនថាយើងទាំងពីរគ្រាន់តែជាអ្នកបំរើគ្មានសារៈប្រយោជន៍អ្វីទេ ប្រសិនបើប្រៀបធៀបទៅនឹងព្រះជាម្ចាស់ ហើយក៏មិនមែនប្រលងប្រណាំងជាមួយគ្នាឡើយ ប៉ុន្តែពឹងពាក់គ្នា ទៅវិញទៅមក[១៥] ។ ក្នុងនាមជាអ្នកបំរើ គាត់យល់ព្រមរងទុក្ខសំរាប់ក្រុមជំនុំ ហើយគាត់តែងតែធ្វើជានិច្ច[១៦] ។ ដោយព្រោះតែគាត់ធ្វើយ៉ាងដូច្នេះ បានជាគាត់

---

[14] *១ពង្សាវតាក្សត្រ ១២:១-១៩*

[15] *១កូរិនថូស ៣:៥-៨*

[16] *២កូរិនថូស ៣:៨-១០; កីលីព ២:១៧; កូលុស ១:២៤-២៥ ។ល។*

ក្លាយទៅជា អ្នកដឹកនាំដ៏អស្ចារ្យម្នាក់ ដែលគ្រីស្ទបរិស័ទ នៅតែគោរព និងដើរតាមរហូតដល់សព្វថ្ងៃនេះ ។

ស្រដៀងគ្នាផងដែរ ប្រសិនបើយើងសព្វថ្ងៃនេះ ប្រាថ្នាចង់ឲ្យគេចងចាំដូចលោកប៉ុល មិនមែនដូច រេហូបោម យើងត្រូវតែរំលឹកឡើងវិញ និងអនុវត្តនូវដំបូន្មានរបស់ព្រះយេស៊ូ "បើអ្នកណាចង់ធ្វើជាលេខ១ នោះត្រូវទៅជាចុងបង្អស់វិញ ហើយត្រូវបំរើគេទាំងអស់ដែរ"[១៧] ។

## អ្នកដឹកនាំល្អគឺជាអ្នកកសាង

អ្នកដឹកនាំខ្លះគិត ថាមធ្យោបាយដែលប្រសើរក្នុងការដែលគេប្រើឋានៈរបស់ខ្លួនបាន គឺជាការដែលគេរក្សាទ្រព្យសម្បត្តិ អំណាច និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឲ្យមានសុវត្ថិភាព ។ កិច្ចការពិតប្រាកដរបស់គេគឺមិនជាការជួយអ្នកដទៃទេឡើយ ។ ពួកគេចាប់អារម្មណ៍តែទៅលើសុខមាលភាព ឬភាពរីកចំរើននៃសមាជិក និងអ្នកនៅពីក្រោមគេ ក្នុងករណីណាដែលការទាំងអស់នោះជួយលើកទឹកចិត្ត និងផ្គត់ផ្គង់ពួកគេតែប៉ុណ្ណោះ ។ ប្រសិនបើអ្នកដឹកនាំដទៃទៀតនៅក្នុងអង្គភាព ចាប់ផ្តើមងើបឡើងនៅក្នុងអំណាច ឬភាពល្បីល្បាញ គឺគាត់បានពិចារណាថា ជាសញ្ញាដែលគាត់ត្រូវទំលាក់ពួកនោះចុះវិញហើយ ។

អ្នកដឹកនាំណាដែលគិតតែនៅក្នុងផ្លូវនេះ លទ្ធផលរបស់ពួកគេគឺមានតែការភ័យខ្លាច ចំពោះអ្នកដែលធ្វើការនៅក្រោមខ្លួន បានទទួលជោគជ័យ ។ ពួកគេមិនចង់រួមចំណែក ដើម្បីទទួលនូវជំនាញថ្មីទៀតដែលពួកគេខ្វះខាតនោះទេ ឬតែងតែមានបំណងចង់ឲ្យគេឃើញខ្លួនជាចំហថាខ្លួនឯងខ្ពង់ខ្ពស់នៅក្នុងការបំរើព្រះ ។ ពួកគេគិតថា ប្រសិនបើមាន

---

[17] ម៉ាកុស ៩:៣៥

អ្នកដទៃណាបានទទួលជំនាញយ៉ាងច្រើន ឬមានការទទួលស្គាល់យ៉ាងច្រើននោះ ឋានៈរបស់គេនឹងត្រូវបានគេដណ្តើមយកពីខ្លួន ។ ការភ័យខ្លាចចំពោះអ្នកដែលគិតតែពីស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួននោះ បណ្តាលឲ្យមានភាពរំខាន មានការអាប់កេរ្តិ៍ឈ្មោះជាសាធារណៈ និងបង្អាញ ឬធ្វើឲ្យមានផ្កាភ្លើងកើតឡើង ។ ប្រហែលជាគេបញ្ជូនឲ្យទៅបរិមណ្ឌល ឬការងារណាមួយ ដើម្បីឲ្យទទួលបរាជ័យនោះពិតប្រាកដណាស់ពួកគេនឹងរិះគន់ ។ ភាពស្រុតចុះខ្លះបណ្តាលឲ្យមានការកើតរឿងអាស្រូវ ការគំរាមកំហែង ឬធ្វើឲ្យមានការឈឺចាប់ខាងឯផ្លូវកាយ ។

ផ្ទុយទៅវិញ អ្នកដឹកនាំដែលល្អកសាងអ្នកដែលនៅក្រោមខ្លួនឡើង ហើយមានអំណរនៅពេលដែលពួកគេទទួលបានជោគជ័យ ។

អេភេសូរ ៤:១១-១៦ ប្រាប់អំពីមូលហេតុអ្វីដែលព្រះគ្រីស្ទផ្តល់អំណោយទានខាងវិញ្ញាណដល់មនុស្សម្នាក់ៗ គឺមិនមែនដើម្បីឲ្យពួកគេមានភាពអំនួត និងអំណាចនោះទេ។ អំណោយទានដែលទ្រង់ប្រទានមកគឺ "ដើម្បីរៀបចំរាស្ត្ររបស់ព្រះសំរាប់ធ្វើការជំនួយ" (ខ.១២) ។ អំណោយទានដែល ខ្ញុំមានមិនមែនដើម្បីឲ្យមនុស្សគិតថាខ្ញុំអស្ចារ្យនោះទេ ប៉ុន្តែបំពាក់បំប៉នខ្ញុំដើម្បីជួយអ្នកឯទៀត ដើម្បីឲ្យគេអាចធ្វើការជំនួយដូចជាខ្ញុំបានដែរ ។ អ្នកដឹកនាំដែលល្អមិនមែនព្យាយាមធ្វើការទាំងអស់តែម្នាក់ឯង ដើម្បីរក្សាអំណាចទាំងអស់សំរាប់តែខ្លួនឯង ហើយគ្មានការអភិវឌ្ឍន៍ជំនាញអ្វីដល់អ្នកណាម្នាក់នោះទេ ។ ប៉ុន្តែអ្នកដឹកនាំដែលល្អពិតនោះគឺធ្វើការសង់អ្នកដទៃឡើង ផ្តល់អំណាចដល់គេ និងជួយពួកគេ ហើយមានភាពអំណរនៅពេលដែលពួកគេបានទទួលជ័យជំនះ ។ ទាល់តែយើងគ្រប់គ្នានៅក្នុងក្រុមជំនុំធ្វើការទាំងអស់គ្នា មិនមែនធ្វើការតែគ្រូគង្វាលម្នាក់ឯងនោះទេ នោះទើប "រូបកាយរបស់ព្រះគ្រីស្ទ ត្រូវបានសង់ឡើង" ហើយ "យើងរាល់គ្នាបានរួបរួម ខាងឯសេចក្តីជំនឿរួចជា

ស្រេច ហើយបានស្គាល់ព្រះរាជបុត្រានៃព្រះ ដូចគ្នាទាំងអស់ គឺដល់បាន ពេញជាមនុស្ស ” (ខ. ១៣) ។

ដូច្នេះក្នុងនាមជាអ្នកដឹកនាំក្រុមជំនុំល្អ សូមបន្តសួរខ្លួនឯងថា “តើអញកំពុងព្យាយាមធ្វើការទាំងអស់តែម្នាក់ឯង ហើយបិទឱកាសមិន ឲ្យអ្នកដទៃធ្វើការ ដើម្បីឲ្យអំណាចទាំងអស់មានតែនៅខ្លួនអញម្នាក់ឯង ឬ?” ឬអញកំពុងកសាងអ្នកដទៃឡើង ដើម្បីឲ្យពួកគេជំនួសកន្លែងអញ បាន ។ តើយើងបានបង្រៀនអ្នកឯទៀតឲ្យចេះសិក្សាព្រះគម្ពីរដោយខ្លួន ឯង ហើយឬនៅ? តើយើងបង្ហាញអ្នកឯទៀតឲ្យចេះកាន់លុយឲ្យបានត្រឹម ត្រូវហើយឬនៅ ដើម្បីឲ្យពួកគេចេះចំណាយដោយឈ្លាសវៃ ហើយទុក ដាក់ដោយស្មោះត្រង់ចំពោះសាធារណៈ? តើយើងមានបង្រៀនអ្នកឯ ទៀតឲ្យ ចេះបង្រៀន និងចេះអធិប្បាយហើយឬទេ ព្រមទាំងផ្តល់ឱកាស ឲ្យពួកគេអនុវត្តដែរឬទេ? ទាំងនេះគឺជាកិច្ចការដែលអ្នកដឹកនាំល្អត្រូវធ្វើ ពួកគេត្រូវតែកសាងអ្នកដទៃឡើង ដើម្បីឲ្យពួកគេទទួលតំណែងបន្ត ។

អ្នកដឹកនាំខ្លះ ខ្លាចក្នុងការធ្វើដូច្នេះ ពីព្រោះគេខ្លាចថា នៅពេល មួយដែលសិស្សរបស់គេធ្វើការបានល្អប្រសើរជាងខ្លួន នោះពួកគេនឹង មានអំណាច ហើយមានការទទួលស្គាល់ខ្លាំងជាង ។ វាជាការពិត ហើយ អាចកើតឡើងបានមែន ។ ប៉ុន្តែវាមិនអីទេ ។ សិស្សរបស់លោកយ៉ូហាន បាបទីស្ទ មានការច្រណែនជំនួសលោក នៅពេលដែលពួកគេឃើញ ព្រះ យេស៊ូបានចាប់ផ្តើមព័ន្ធកិច្ចរបស់ព្រះអង្គ ពីព្រោះមានមនុស្សជាច្រើនចាប់ ផ្តើមចាកចេញពីលោក យ៉ូហាន ទៅតាមព្រះយេស៊ូ ។ ប៉ុន្តែលោក យ៉ូហាន និយាយថា “ត្រូវឲ្យព្រះអង្គនោះបានចំរើនឡើង ហើយខ្ញុំត្រូវថយវិញ”[១៨]។ លោកអនទ្រេបាននាំបងរបស់គាត់គឺលោក ស៊ីម៉ូន ពេត្រុស ទៅចំពោះ

---

[18] *យ៉ូហាន ៣:៣០*

ព្រះយេស៊ូ[19] ហើយក្រោយមកលោកពេត្រុសមានភាពល្បីល្បាញជាង លោក អនទ្រេ ។ នៅពេលដែលលោក សុល នៃតាសុស បានមកដល់ សេចក្តីជំនឿ ក្រុមជំនុំដំបូងគិតថា ការប្រែចិត្តរបស់គាត់ គឺជាល្បិចកល ។ ប៉ុន្តែបាណាបាសបានជឿទៅលើសុល ព្រមទាំងណែនាំគាត់ទៅដល់ ក្រុមជំនុំទៀតផង[20] ។ មិនយូរប៉ុន្មាន សុល ដែលជា សាវ័ក ប៉ុល បានក្លាយ ទៅជាអ្នកដ៏ខ្លាំងក្លាម្នាក់ និងមានឈ្មោះល្បីជាង បាណាបាស ។ ប៉ុន្តែ ប្រសិនបើយើងមានសេចក្តីស្រឡាញ់ចំពោះព្រះយេស៊ូ ហើយមានឆន្ទៈ ដ៏ជ្រាលជ្រៅ ដើម្បីឲ្យព្រះនាមព្រះបានថ្កើងឡើង និងឲ្យគេទទួលស្គាល់ នោះ ពិតជាមិនអីទេចំពោះយើង ប្រសិនបើទ្រង់ប្រើអ្នកដែលយើង ហ្វឹកហ្វឺនច្រើនជាងខ្លួនយើងក៏ដោយ ។ ព្រោះព័ន្ធកិច្ចទាំងអស់ គឺជា ជ័យជំនះរបស់ក្រុមជំនុំ និងថ្វាយព្រះកិត្តិនាមដល់ព្រះយេស៊ូ មិនមែនជា ជ័យជំនះរបស់យើង ឬផ្តល់កិត្តិនាមដល់ខ្លួនយើងនោះទេ ។

នៅក្នុងសតវត្សទី ១៩ គ្រូសាលារៀនថ្ងៃអាទិត្យដ៏ភ័យខ្លាចមួយ នៅក្នុងសហរដ្ឋអាមេរិក បានទៅតូបលក់ស្បែកជើងដើម្បីចែកចាយ ដំណឹងល្អដល់អ្នកលក់ស្បែកជើងម្នាក់ ។ យើងភាគច្រើនមិនបានស្គាល់ ឈ្មោះគ្រូសាលារៀនថ្ងៃអាទិត្យនោះទេ ប៉ុន្តែយើងភាគច្រើនធ្លាប់ឮអំពីអ្នក លក់ស្បែកជើង។ ឈ្មោះរបស់គាត់គឺ ដ្វៃ ម៉ូឌី (Dwight L. Moody) ព្រះបានប្រើគាត់ជាអ្នកផ្សាយដំណឹងល្អដ៏អស្ចារ្យម្នាក់ ។ សព្វថ្ងៃនេះ សាលារៀន ព័ន្ធកិច្ចវិទ្យុ និងរោងពុម្ព បានដាក់ឈ្មោះគាត់ ។ អ្នកដើរ តាមបានរីកលូតលាស់ជាងអ្នកដឹកនាំ ប៉ុន្តែខ្ញុំដឹងពិតប្រាកដថា គ្រូសាលា រៀនថ្ងៃអាទិត្យដ៏ភ័យខ្លាចម្នាក់នោះគិតថា វាជាការប្រពៃណាស់ ។

---

[19] *យ៉ូហាន ១:៤០-៤១*

[20] *កិច្ចការ ៩:២៦-២៨*

ដូច្នេះយើងសរុបមកវិញថា អ្នកដឹកនាំគ្រីស្ទបរិស័ទដែលល្អ គឺជាអ្នកដែលមិនផ្ដោតទៅលើសុវត្ថិភាព និងការតំកើងខ្លួនឯង ។ ប៉ុន្តែគាត់បង្រៀនអ្នកដទៃទៀត ដើម្បីឲ្យពួកគេអាចទទួលកន្លែងបន្តពីគាត់ ។

## អ្នកដឹកនាំល្អគឺជាអ្នកនាំមុខ

យើងបាននិយាយជាច្រើនមកហើយអំពីអ្នកដឹកនាំជាអ្នកដើរតាមជាអ្នកបំរើ និងជាអ្នកកសាងអ្នកដទៃឡើង ។ ប្រសិនបើទាំងអស់នេះគ្រប់គ្រាន់ហើយចំពោះអ្វី ដែលព្រះគម្ពីរបានបង្រៀនទៅលើប្រធានបទនេះ នោះយើងអាចសរុបបានថា អ្នកដឹកនាំនឹងមិនដែលក្លាយទៅជាអ្នករឹងមាំ ឬជាអ្នកមិនរុញរានោះបានឡើយ ។ ប្រសិនបើអ្នកដឹកនាំជាអ្នកដើរតាមល្អ ជាអ្នកបំរើ ហើយជាអ្នកកសាងអ្នកដទៃឡើងមែន នោះតើវាត្រឹមត្រូវទេដែលថា គាត់ត្រូវតែឈរនៅខាងមុខ ហើយបង្ហាញនូវសេចក្ដីក្លាហានព្រមទាំងផ្ដល់នូវការណែនាំដ៏មុឹងម៉ាត់នោះ?

ចំលើយទៅចំពោះសំណួរនេះ គឺពិតជា "ត្រឹមត្រូវណាស់" ។ ក្នុងខណៈពេលដែលវាជាការពិត អ្នកដឹកនាំគ្រីស្ទបរិស័ទ ដូចជាព្រះយេស៊ូជាដើម ព្រះអង្គស្វះស្វែងក្នុងការបំរើជាជាងឲ្យគេមកបំរើព្រះអង្គ និងដូចជាលោក ប៉ុល កសាងព័ន្ធកិច្ចរបស់អ្នកដទៃឡើង ជាជាងផ្ដោតការចាប់អារម្មណ៍តែទៅលើខ្លួនឯង កន្លែងនេះមិនមែនមានន័យថា គាត់ជាអ្នករុញរានោះទេ ។ តែផ្ទុយទៅវិញ អ្នកដឹកនាំគឺជាអ្នកដែលនាំមុខគេ ។ គាត់ធ្វើការចាប់ផ្ដើមចង្អុលផ្លូវ ហើយដាស់តឿនមុនមានគ្រោះថ្នាក់ ។ គាត់មិនត្រូវអង្គុយ ហើយរង់ចាំអ្នកដទៃ ឬរង់ចាំព្រះ ឲ្យធ្វើការអ្វីមួយឡើយ ។ អ្នកដឹកនាំល្អបំរើដោយនាំមុខគេ ។

ពេលខ្លះមនុស្សទទួលនាមជាអ្នកដឹកនាំ ប៉ុន្តែចាកចោលការងារពិតនៃការនាំមុខអ្នកដទៃ ។ ឧទាហរណ៍ ស្ដេចសូល គឺជាស្ដេចទីមួយ

នៃអ៊ីស្រាអែល ។ ក្នុងឋានៈជាស្ដេច ទ្រង់គឺជាអ្នកដឹកនាំអ៊ីស្រាអែល ។ ដូច្នេះ នៅពេលដែលយ័ក្ស កុលលីយ៉ាត បបួលអ៊ីស្រាអែលធ្វើសង្គ្រាម ស្ដេចសូលត្រូវតែជាអ្នកដែលទទួលនូវការបបួលនេះ ។ ប៉ុន្ដែទ្រង់បែរជាអង្គុយនៅក្នុងត្រសាលរបស់ទ្រង់ ក្រោមការបំពាក់នាមជាអ្នកដឹកនាំទៅវិញ ។ តាមពិត ទ្រង់ត្រូវតែងើបឡើងនៅក្នុងកំលាំងនៃព្រះ ហើយដឹកនាំ ។ តែទីបំផុតបែរជាមានអ្នកគង្វាលដាវីឌដ៏តូចម្នាក់ ជាអ្នកដែលគ្មានឋានៈ បានងើបឡើងយ៉ាងខ្លាំងក្លានៅក្នុងកំលាំងនៃព្រះ ហើយដឹកនាំ អ៊ីស្រាអែល នៅក្នុងថ្ងៃដ៏ស្លាប់រស់នោះប្រឆាំងនឹងសត្រូវរបស់ខ្លួនទៅវិញ ។ វាជាកំហុសរបស់ស្ដេចសូល ។ នៅពេលដែលទាហានវិលត្រឡប់ពីសង្គ្រាមមកវិញ ស្រីៗបានចេញមកជួបពួកគេ ហើយអបអរសាទរ ដាវីឌជាងអបអរស្ដេច ដោយនិយាយថា "ស្ដេចសូលបានសំលាប់តែមួយពាន់ តែដាវីឌបានសំលាប់មួយម៉ឺនវិញ" ។

នេះមិនមែនជាលើកដំបូងទេដែលស្ដេចសូល មានឋានៈជាស្ដេចផង និងជាអ្នកដឹកនាំផងបានទទួលបរាជ័យក្នុងការដឹកនាំនោះ ។ នៅក្នុងសាំយូអែល ១៤:១ បុត្រារបស់ស្ដេចសូល យ៉ូណាថាន់ បានចាប់ផ្ដើមទុកចិត្តព្រះ ដោយនាំពួកអ៊ីស្រាអែលប្រយុទ្ធតទល់ទៅនឹងសត្រូវរបស់ ខ្លួន ។ ខ. ២ បានបង្ហាញឲ្យយើងឃើញនូវអ្វីដែលស្ដេចកំពុងធ្វើ គឺទ្រង់អង្គុយក្រោមដើមទទឹមជាមួយទាហានរបស់ទ្រង់ ៦០០នាក់ ។ បន្ទាប់មកនៅក្នុង ជំពូក១៥ ទ្រង់ទទួលសំណូមពរពីអ្នកដទៃ ដែលចូលទៅក្នុងការមិនស្ដាប់បង្គាប់ទៅនឹងព្រះរាជបញ្ជារបស់ព្រះ ទ្រង់មិនបានឈរនៅក្នុងជំហរ ហើយដឹកនាំប្រឆាំងទៅតាមសេចក្ដីប្រាថ្នារបស់ពួកគេ ។ វាគ្មានការសង្ស័យឡើយ គឺរាជវង្សរបស់សូលមិននៅគង់វង្សយូរអង្វែងទៀតឡើយ ហើយព្រះបានរកឃើញម្នាក់ផ្សេងទៀតដែលដឹកនាំរាស្ត្ររបស់ទ្រង់តាមព្រះហឫទ័យរបស់ទ្រង់វិញ ។

ការនាំមុខមានន័យថា ពេលខ្លះយើងត្រូវតែមានជំហរឲ្យបានរឹង មាំ និងពេលខ្លះមានជំហរតែម្នាក់ឯង ។ ព្រោះពេលខ្លះប្រហែលជាអ្នក ដទៃគេមានការភ័យខ្លាច ឬគេងលក់ ឬធ្វើជាមិនដឹង ហើយដើរចុះផ្លូវមួយដែលខុស ។ ដូច្នេះហើយ នៅពេលដែលអ្នកដឹកនាំឈរយ៉ាងខ្ពស់ ហើយនិយាយយ៉ាងខ្លាំងក្លាទៅលើអ្វីដែលត្រូវតែធ្វើឲ្យបានសំរេច សូម្បីតែការធ្វើរបស់គាត់មិនឲ្យគាត់ល្បីល្បាញក៏ដោយ ។ គាត់ធ្វើយ៉ាងដូច្នេះមិនមែនដើម្បីសាងឋានៈរបស់ខ្លួនឡើយ ប៉ុន្តែសំរាប់សេចក្ដីពិតវិញ ។ លោកអេលីយ៉ាជាអ្នកដឹកនាំដ៏ខ្លាំងក្លាម្នាក់ ដែលគាត់ងើបឈរតែម្នាក់ឯងប្រឆាំងនឹងយេសេបែលដែលមានហោរ៉ារបស់ព្រះបាល ៨០០នាក់ ។ គាត់ធ្វើយ៉ាងដូច្នេះមិនមែនសំរាប់ខ្លួនឯងទេ ប៉ុន្តែសំរាប់សេចក្ដីពិត ។ លោក យេរេមា និងហោរ៉ាសញ្ញាចាស់ផ្សេងៗទៀត តែងតែឈរនៅក្នុងជំហរដែលមិនល្បីល្បាញ ។ លោកប៉ុលប្រឆាំងទៅនឹងលោកពេត្រុសទល់មុខតែម្ដងនៅក្នុង កាឡាទី ជំពូក២ ។ គាត់ធ្វើយ៉ាងដូច្នេះមិនមែនដើម្បីចង់ចំណោញអំណាចមកលើខ្លួនគាត់ ឬចំណោញកេរ្ដិ៍ឈ្មោះមកពីពេត្រុស នោះទេ ប៉ុន្តែពីព្រោះតែពេត្រុសបានធ្វើខុស ។ លោកពេត្រុសត្រូវការការកែរតំរង់ មុនដែលគាត់នាំមួយផ្នែកធំនៃក្រុមជំនុំចូលទៅក្នុងភាពខុសឆ្គង ។

ដូច្នេះទោះបីជាអ្នកដឹកនាំល្អ ទីមួយគឺដើរតាម និងមិនមែនបោកបញ្ឆោតអ្នកដទៃតាមរយៈការហ៊ឹកហ៊ឺន និងឱកាសផ្សេងៗដើម្បីធ្វើឲ្យគ្រប់គ្នាមានការចាប់អារម្មណ៍មកលើខ្លួនឯងនោះឡើយ ។ នៅពេលនោះគាត់មានការបំរើដោយអស់ពីចិត្ត ដោយឈរក្នុងជំហរដ៏រឹងមាំ ហើយបង្ហាញផ្លូវពួកគេនូវផ្លូវណាដែលត្រូវទៅ ។ អ្នកដឹកនាំល្អបំរើដោយការនាំមុខគេ។

ពីព្រោះតែអ្នកដឹកនាំត្រូវតែនាំមនុស្សរបស់គេ ជាដំបូងគាត់ត្រូវដឹងទិសដៅពិតប្រាកដដែលត្រូវទៅ ។ ហេតុដូច្នេះហើយបានជាតំរូវឲ្យ

គាត់ជាអ្នកដើរតាមល្អជាមុនសិន ។ អ្នកដឹកនាំត្រូវតែនាំ ប៉ុន្តែប្រសិនបើគាត់មិនដឹងកន្លែងណាដែលគាត់ត្រូវទៅពិតប្រាកដទេ នោះមានន័យថាគាត់មិនទាន់បានដើរកៀកជាមួយព្រះជាម្ចាស់នៅឡើយទេ ប្រហែលជាគាត់នាំចៀមរបស់គាត់ទៅរកភាពគ្រោះថ្នាក់ហើយ ។ នេះគឺជាអ្វីដែលព្រះយេស៊ូវទ្រង់មានបន្ទូល នៅពេលដែលទ្រង់និយាយអំពីពួកផារិស៊ី "តាមតែគេចុះ គេជាមនុស្សខ្វាក់ដែលនាំមនុស្សខ្វាក់ បើមនុស្សខ្វាក់នាំមនុស្សខ្វាក់យ៉ាងដូច្នេះ នោះទាំងពីរនឹងធ្លាក់ទៅក្នុងរណ្តៅហើយ"[២១] ។ ពួកផារិស៊ីមិនបានដើរតាមព្រះអម្ចាស់ទេ ។ ដូច្នេះទោះបីជាពួកគេបានធ្វើការងារពួកគេក្នុងនាមជាអ្នកនាំមុខគេក៏ដោយ ពួកគេមិនដឹងថានឹងទៅកន្លែងណាទេ ហើយនាំចៀមរបស់គេឲ្យធ្លាក់រណ្តៅទៅវិញ ។ អ្នកដឹកនាំល្អស្គាល់ផ្លូវដែលគាត់ត្រូវទៅ ហើយបន្ទាប់មកខំពុះពារយ៉ាងខ្លាំងក្លាដោយសេចក្តីក្លាហាន ដោយនាំមនុស្សរបស់គេទៅរកផ្លូវនោះ ។

## អ្នកដឹកនាំល្អគឺជាអ្នកដែលហុចកំណាត់ឈើរត់ប្រណាំងបន្តទៅឲ្យអ្នកដទៃ

ល្បែងរត់ប្រណាំងគឺជាកីឡាដ៏ល្បីល្បាញមួយ ។ កីឡាកររទ្រោបចុះពីក្រោយខ្សែបន្ទាត់ និងនៅពេលដែលកាំភ្លើងត្រូវបានបាញ់ឡើង គ្រប់គ្នាត្រូវចាប់ផ្តើមរត់ឆ្ពោះទៅរកទីដៅរៀងៗខ្លួន ។ ការប្រកួតភាគច្រើន គឺមានតែម្នាក់ៗ ។ អ្នកប្រកួតនីមួយៗ ដែលមានតែម្នាក់ៗ គឺខ្លួនគេនោះឯងជា "ក្រុម" របស់គេ ។ ទោះជាគេធ្វើយ៉ាងណា ចាញ់ ឬឈ្នះ គឺស្ថិតលើខ្លួនរបស់គេផ្ទាល់ ។ គាត់គ្មានដៃគូទេ ។ ប៉ុន្តែការប្រកួតខ្លះមានក្រុមដៃគូមួយក្រុម ។ ក្រុមដៃគូមួយក្រុមនោះប្រហែលជាមាន សមាជិក ៤នាក់ ។ នៅពេលដែលការប្រកួតចាប់ផ្តើម អ្នកដែលមានតួនាទីហុចកំណាត់ឈើតូចមួយឲ្យសមាជិកទីមួយកាន់ ។ នៅពេលដែលកាំភ្លើងបាញ់ឡើង

---

[21] *ម៉ាថាយ ១៥:១៤*

សមាជិកទីមួយនេះ រត់ជុំវិញទីលានដោយកាន់កំណាត់ឈើនេះជាប់ទៅ នឹងដៃ ។ បន្ទាប់មក នៅពេលដែលគេរត់មកដល់កន្លែងដើមវិញហើយ សមាជិកទីពីរដែលកំពុងរង់ចាំ រត់តាមដើម្បីទទួលកំណាត់ឈើពីសមាជិកទីមួយ ចំណែកឯសមាជិកទីមួយបញ្ចប់ជុំរបស់គេហើយ ។ សមាជិកទីពីរ នៅពេលដែលទទួលកំណាត់ឈើរួចហើយ ក៏រត់ជុំទីលានបន្តទៀត ។ នៅពេលដែលគាត់រត់ជុំទីលាន ហើយជិតដល់បន្ទាត់ចាប់ផ្ដើមវិញហើយ សមាជិកទីបីនៃក្រុមនោះកំពុងរង់ចាំ ។ ម្ដងទៀត កំណាត់ឈើមួយនោះត្រូវហុចឲ្យម្នាក់ទៀត ដោយសមាជិកទីពីរហុចឲ្យសមាជិកទីបីទទួល ។ ដំណើរការណ៍នេះបន្តរហូតដល់សមាជិកទាំងអស់នៅក្នុងក្រុមមានឱកាសរត់ជុំវិញទីលាន ដែលកាន់កំណាត់ឈើជាប់នឹងដៃ ។ អ្នកដែលឈ្នះនៅក្នុងការប្រកួតនេះ មិនមែនម្នាក់ណាមួយទេ ប៉ុន្តែជាក្រុមដែលរត់ជាមួយគ្នាបានយ៉ាងល្អ មិនរអាក់រអួល និងហុចកំណាត់ឈើបានយ៉ាងត្រឹមត្រូវ ។ ប្រសិនបើមានសមាជិកណាម្នាក់នៅក្នុងក្រុមមិនបានសហការល្អជាមួយអ្នកឯទៀត ដូចជាអ្នកដែលរត់ជាមួយដើម្បីទទួលកំណាត់ឈើ និងអ្នកដែលត្រូវហុចកំណាត់ឈើឲ្យអ្នកដែលទទួលដើម្បីកាន់ឲ្យបានជាប់ល្អនោះទេ នោះពួកគេមិនអាចឈ្នះបានឡើយ ។ ទោះបីជាម្នាក់ៗនៅក្នុងក្រុមមានការរត់លឿនជាងគេបំផុតយ៉ាងណាក៏ដោយ ប្រសិនបើគេមិនបានហុចឲ្យបានល្អ និងអ្នកទទួលមិនបានទទួលយកឲ្យបានត្រឹមត្រូវ នោះក្រុមរបស់គេនឹងចាញ់ជាមិនខាន ។ ការរត់ប្រណាំងជាក្រុម មិនមែនធ្វើឡើងដោយម្នាក់ៗឯងនោះទេ ប៉ុន្តែជាការធ្វើឡើងជាក្រុមវិញ ។

ភាពជាអ្នកដឹកនាំគ្រីស្ទបរិស័ទគឺយ៉ាងដូច្នេះឯង ។ យើងមិនមែនស្ថិត នៅក្នុងថ្នាក់ដឹកនាំដើម្បីធ្វើឲ្យគេមានចាប់អារម្មណ៍មកលើយើងថា យើងដឹកនាំ ឬផ្សព្វផ្សាយដំណឹងល្អ ឬបង្រៀន ឬអធិប្បាយបានល្អនោះទេ ។

យើង គ្រាន់តែជាផ្នែកមួយនៃក្រុមដែលយើងត្រូវបានត្រាស់ហៅឲ្យទទួលចំណែកដើម្បីអាចធ្វើការយ៉ាងប្រសើរដែលអាចធ្វើបាន ហើយបន្ទាប់មកហុចកំណាត់ឈើឲ្យអ្នកដទៃទៀត ។

ព័ន្ធកិច្ចគ្រីស្ទបរិស័ទបានចាប់ផ្ដើមឡើងជាមួយព្រះយេស៊ូ ។ នៅពេលមួយចូលមកដល់ ទ្រង់ត្រូវបញ្ចប់ព័ន្ធកិច្ចរបស់ទ្រង់ដោយសុគតសំរាប់យើង ត្រូវបានរស់ឡើងវិញ ហើយវិលត្រឡប់ទៅឯនគរស្ថានសួគ៌ ទ្រង់បានហុចកំណាត់ឈើនៃព័ន្ធកិច្ចឲ្យសាវ័ករបស់ព្រះអង្គ ។ ទ្រង់បានមានព្រះបន្ទូលទៅពួកគេថា "តែឥឡូវនេះ ខ្ញុំទៅឯព្រះអង្គដែលចាត់ឲ្យខ្ញុំមក... ប៉ុន្តែអ្នករាល់គ្នាមានចិត្តពេញដោយសេចក្តីព្រួយ ។ ខ្ញុំប្រាប់តាមត្រង់ថា ដែលខ្ញុំទៅនោះមានប្រយោជន៍ដល់អ្នករាល់គ្នាវិញ ដ្បិតបើខ្ញុំមិនទៅទេ នោះព្រះដ៏ជាជំនួយក៏មិនមកឯអ្នករាល់គ្នាដែរ តែបើខ្ញុំទៅ នោះខ្ញុំនឹងចាត់ទ្រង់ឲ្យមក"[២២] ។ ក្រោយមកទៀតទ្រង់មានព្រះបន្ទូលថា "ខ្ញុំចាត់អ្នករាល់គ្នាឲ្យទៅដូចជាព្រះវបិតាបានចាត់ឲ្យខ្ញុំមកដែរ"[២៣] ។ ព្រះយេស៊ូបានចាកចេញ ព្រះអង្គបានប្រគល់ការងារដល់ពួកគេ ហើយទ្រង់នឹងបញ្ជូនព្រះ វិញ្ញាណដ៏វិសុទ្ធមកដើម្បីជួយពួកគេឲ្យសំរេចការទាំងអស់នោះបាន ។

ដូច្នេះ ពួកសាវ័កទទួលបន្តពីកន្លែងដែលព្រះយេស៊ូបានបញ្ឈប់។ ព្រះគម្ពីរសញ្ញាថ្មីបាននិយាយអំពីសាវ័ករបស់ព្រះយេស៊ូថា ជាអ្នកដាំជើងជញ្ជាំងនៃក្រុមជំនុំ[២៤] ។ ប៉ុន្តែពួកសាវ័កមិនបានធ្វើរហូតតទៅនោះទេ តាមរយៈពួកគេខ្លះបានធ្វើយ៉ាងល្អ និងព័ន្ធកិច្ចរបស់គេបានចាប់ផ្តើមក្រុមជំនុំ ។ ពេលមួយមកដល់ គឺពួកគេត្រូវប្រគល់ការងារនោះទៅអ្នកឯទៀត

[22] *យ៉ូហាន ១៦:៥-៧*

[23] *យ៉ូហាន ២០:២១*

[24] *១កូរិនថូស ៣:១០-១២: អេភេសូរ ២:២: វិវរណៈ ២១:១៤*

។ ចូរមើលពីគំរូសាវ័កប៉ុលទុកជាឧទាហរណ៍ គឺគាត់ត្រូវបានបញ្ជូនផ្ទាល់ដោយ ព្រះគ្រីស្ទ គាត់បានធ្វើការងាររបស់គាត់បានល្អ ហើយបន្ទាប់មកបានប្រគល់ការងាររបស់គាត់នោះទៅឲ្យធីម៉ូថេទទួលវិញ ដោយលោកប៉ូល ផ្តល់ការណែនាំដ៏សំខាន់ៗដល់សិស្សរបស់គាត់ដោយនិយាយថា "ឯអស់ទាំងសេចក្តីដែលអ្នកបានឮអំពីខ្ញុំ នៅមុខស្មរបន្ទាល់ជាច្រើន នោះក៏ត្រូវផ្ញើទុកនឹងមនុស្សស្មោះត្រង់ ដែលអាចនឹងបង្រៀនតទៅអ្នកឯទៀតដែរ"[២៥] ។ ធីម៉ូថេបានទទួលកំណាត់ឈើមកពីសាវ័ក ប៉ុល រត់ក្នុងទីលានរបស់គាត់ ហើយបន្ទាប់មកប្រគល់កំណាត់ឈើឲ្យអ្នក "ស្មោះត្រង់" ដែលអាចរត់ក្នុងទីប្រណាំងបាន ហើយបន្ទាប់មកទៀតអាច "បង្រៀនដល់អ្នកឯទៀត" ។ ព័ន្ធកិច្ចគ្រីស្ទបរិស័ទ មិនមែនជាការរត់ប្រណាំងម្នាក់ឯងនោះទេ ហើយក៏មិនមែនខំប្រឹងប្រែងដើម្បីឲ្យគេចាប់អារម្មណ៍ថាខ្លួនឯងជាតួឯក និងជាវិរបុរសនោះដែរ ។ វាជាការរត់ប្រណាំងជាក្រុម នៅពេលដែលយើងទទួលព្រះបន្ទូលហើយ នោះយើងជាអ្នកដំបូងដែលត្រូវចែកចាយព្រះបន្ទូលនេះដល់អ្នកឯទៀត បន្ទាប់ពីយើងរត់ក្នុងទីលានដ៏ខ្លីរបស់យើងរួចហើយ ស្វែងរកនរណាម្នាក់ដែលយើងអាចផ្ទេរការងាររបស់យើង ឲ្យទទួលខុសត្រូវជំនួសយើងបាន ។

ក្នុងនាមជាអ្នកដឹកនាំ យើងត្រូវតែព្យាយាមស្វែងរកមនុស្សល្អៗមួយចំនួនតូច ដែលយើងអាចបណ្តាក់ទុនកំលាំងរបស់យើងបន្ថែម ដើម្បីឲ្យថ្ងៃមួយ ពួកគេអាចទទួលដោយស្រួល និងមានដំណើរការល្អ ។ ដូចជាការរត់ប្រណាំងជាក្រុម ពួកគេមិនអាចឈ្នះបានទេប្រសិនបើក្រុមមួយធ្លាក់កំណាត់ឈើ ឬមិនបានហុចឲ្យគ្នាឲ្យបានល្អ ដូចគ្នាដែរព័ន្ធកិច្ចគ្រីស្ទបរិស័ទរបស់យើង នឹងជួបនូវការរងទុក្ខប្រសិនបើយើងមិនមាន

---

[25] ២ធីម៉ូថេ ២:២

មនុស្សដែលបានទទួលនូវការហ្វឹកហ្វឺន និងប្រុងប្រៀបដើម្បីទទួលកិច្ចការបន្ត នៅពេលដែលយើងចាកចេញទៅ ។

ដោយព្រោះព្រះយេស៊ូជ្រាបថាមិនយូរទេទ្រង់ត្រូវសុគតលើឈើឆ្កាង ហើយលាចាកផែនដីនេះទៅ បានជាទ្រង់ចំណាយពេលជាច្រើនឆ្នាំចុងក្រោយរបស់ព្រះអង្គ ក្នុងការហ្វឹកហ្វឺនសិស្សរបស់ព្រះអង្គ ។ បន្ទាប់ពីលោកពេត្រុសអាចសរុបបានថា ព្រះយេស៊ូគឺជាព្រះមែស៊ី របស់អ៊ីស្រាអែលរួចមកព្រះយេស៊ូ "ចាប់ផ្តើមពន្យល់សិស្សរបស់ព្រះអង្គថា ទ្រង់ត្រូវតែទៅក្រុងយេរូសាឡិម ហើយត្រូវរងទុក្ខ..."[២៦] ។ វាហាក់បីដូចជាទ្រង់ចំណាយពេលច្រើនជាមួយពួកគេ ហើយភាគតិចជាមួយបណ្តាជន ។ ជំនួសឲ្យធ្វើការប្រកាសដំណឹងល្អតែអង្គទ្រង់ផ្ទាល់គឺទ្រង់បញ្ជូនអ្នកទាំង១២ ហើយក្រោយមកទៀត ៧០នាក់ថែមទៀត ទៅប្រកាសដំណឹងល្អ និងបង្រៀន។ ជាជាងឲ្យទ្រង់ឈរតែម្នាក់ឯង ហើយបង្រៀនគឺទ្រង់ប្រទានឱកាសឲ្យអ្នកដទៃទៀតដើម្បីរៀនពីជំនាញ ទោះបីជាទ្រង់អាចធ្វើល្អជាងពួកគេក៏ដោយ ។ ទ្រង់បានរៀបចំពួកគេឲ្យទទួលកំណាត់ឈើដើម្បីរត់បន្តទៀត ។

ដូច្នេះប្រសិនបើយើងក្លាយជាអ្នកដឹកនាំល្អ យើងមិនមែនគ្រាន់តែធ្វើការងារផ្ទាល់ខ្លួនរបស់យើងបានល្អតែប៉ុណ្ណោះទេ យើងត្រូវតែបន្តក្នុងការហ្វឹកហ្វឺនអ្នកឯទៀតដើម្បីទទួលកន្លែងរបស់យើង ។ តើអ្នកកំពុងធ្វើការនេះហើយឬនៅ? តើអ្នកមានរណាម្នាក់ហើយឬនៅ ដែលជួបជាមួយ អ្នកដើម្បីរៀនព្រះគម្ពីរ និងអធិដ្ឋានជាមួយគ្នា? តើអ្នកបាននាំអ្នកដទៃទៅជាមួយអ្នក នៅពេលដែលអ្នកចេញទៅធ្វើការ ដើម្បីឲ្យគេអាចសង្កេត... និងអាចចែកចាយ... ហើយបន្ទាប់មកអាចជំនួសអ្នកបានហើយឬនៅ?

---

[26] *ម៉ាថាយ ១៦:២១*